អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# យើងអាច គ្រាន់តែតាមវិធីផ្សេងគ្នា

## We Can - Just Differently



Written by TukTuk

Illustrated by Choven Hen




យ៉េកសួរ « នៅថ្ងៃឈប់សម្រាក តើអ្នកទៅដើរលេងនៅភ្នំពេញសប្បាយទេ? »

រតនាឆ្លើយ « ចាស! សប្បាយខ្លាំងណាស់! ទោះបីជាពួកយើងត្រូវទៅសាលាជាមួយមីងរបស់ពួកយើងក៏ដោយ »។



យ៉េកសួរទាំងឆ្ងល់ « អ្នកត្រូវទៅសាលាក្នុងថ្ងៃឈប់សម្រាកទៀត? ធ្វើអីចឹង មិនសប្បាយទេមើលទៅ! » « អូ! សប្បាយទេតើ! អ្នកមីងដារិនធ្វើការនៅឯសាលាសម្រាប់ក្មេងដែលត្រូវការការអប់រំពិសេស។ នៅទីនោះ ពួកយើងបានស្គាល់មិត្តភក្តិល្អៗជាច្រើន »។



មករានិយាយ « នៅម៉ោងសិល្បៈ ខ្ញុំបានអង្គុយជិតក្មេងប្រុសម្នាក់ឈ្មោះទី។ គាត់កើតមក ដោយពិការដៃទាំងសងខាង »។



យ៉េកក៏សួរ « ម៉ោងសិល្បៈ? តើគាត់គូររូបយ៉ាងណាទៅ បើពិការដៃ? »

« គាត់អាចគូរបានទេតើ! គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ប្រើមាត់ដើម្បីគូររូប »។យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



« នៅល្ងាចនោះ ខ្ញុំនិងរតនាបានសាកល្បងធ្វើដូចគាត់ដែរ ប៉ុន្តែយើងបានធ្វើឱ្យថ្នាំពណ៌ប្រឡាក់គ្រប់ទីកន្លែង »។



រតនានិយាយ « ខ្ញុំបានជួបក្មេងស្រីម្នាក់ឈ្មោះចិន្តាដែលនាងពិការភ្នែក។ កាលនោះ នាងកំពុងអានសៀវភៅ »។
យ៉េកសួរ « អានសៀវភៅ? តើនាងអានសៀវភៅយ៉ាងណាទៅ បើនាងពិការភ្នែក? »




រតនាក៏បកស្រាយ « នាងអាចអានបានតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ សៀវភៅរបស់នាង គឺសរសេរឡើងដោយប្រើអក្សរស្ទាប។ តួអក្សរនីមួយៗផុសឡើងមក ហើយនាងអានដោយប្រើម្រាមដៃរបស់នាង »។ យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



« មានក្មេងខ្លះដែលជិះរទេះ បានហៅពួកយើងឱ្យលេងបាល់បោះជាមួយពួកគាត់ »។

យ៉េកសួរ « បាល់បោះ! តើពួកគាត់អាចលេងបាល់បោះតាមរបៀបណាទៅ? » « តើអ្នកទាំងពីរ ត្រូវជិះរទេះដូចពួកគាត់ដែរឬទេ? »



« ពួកគាត់អាចលេងបានទេតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ ពួកយើងរត់ ឯពួកគាត់វិញ បង្វិលកង់រទេះ។ ពួកគាត់បោះចូលសឹងតែរាល់ដង! » យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



« ពួកយើងបានជួបក្មេងប្រុសម្នាក់ឈ្មោះមេសាដែលពិការត្រចៀក។ ពួកយើងបានលេងល្បែងតាថាជាមួយគ្នា »។

យ៉េកសួរ « ល្បែងតាថា! តើធ្វើយ៉ាងណាទើបគាត់ដឹងថាខ្លួនត្រូវធ្វើអ្វី បើគាត់ស្ដាប់មិនឮផងហ្នឹង? »



« គាត់អាចស្ដាប់ឮបាន គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ឈរនៅខាងមុខ ដូច្នេះគាត់អាចមើលមាត់របស់អ្នកគ្រូ ធ្វើយ៉ាងនេះគាត់អាច “ស្ដាប់” អ្នកគ្រូយល់បាន »។



« ដំបូង មីងដារីននិយាយដោយសំឡេងធម្មតា យើងទាំងអស់គ្នាអាចធ្វើបាន។
តែក្រោយមក គាត់ខ្សឹបដោយមិនបញ្ចេញសំឡេងទេ។



ពេលនោះយើងមិនអាចស្ដាប់គាត់ឮ ហើយក៏មិនដឹងថាគួរធ្វើអ្វីដែរ មានតែមេសាទេដែលដឹងនិងយល់ »។
យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



នៅយប់នោះ រតនាបានគិតដល់សំណាងដែលទើបប្ដូរចូលថ្នាក់របស់នាង។ គាត់មានជំងឺអូទីសឹម។ គាត់មិនចូលចិត្តលេងល្បែងទេ ហើយក៏មិននិយាយច្រើនដែរ។



ក្មេងដទៃទៀតនៅក្នុងថ្នាក់គិតថាគាត់ជាក្មេងចម្លែក។

រតនាគិតថា « ប្រហែលជា សំណាងដូចជាក្មេងៗនៅសាលារបស់មីងដារិនអីចឹង។ គាត់អាច គ្រាន់តែតាមវិធីផ្សេង »។



នៅថ្ងៃបន្ទាប់ រតនាបានសួរសំណាង « តើអ្នកចាប់អារម្មណ៍លើរឿងអ្វី? » សំណាងឆ្លើយ « លំហ » ។
បន្ទាប់មក គាត់ក៏ចាប់ផ្ដើមប្រាប់រតនាពីរឿងរ៉ាវជាច្រើនដែលទាក់ទងនឹងភពនិងអវកាសយានិក។



ក្មេងដទៃក៏ចាប់ផ្ដើមចូលរួមស្ដាប់ផងដែរ។ ក្មេងម្នាក់បាននិយាយ « អូ! អស្ចារ្យណាស់! អ្នកដឹងពីរឿងលំហច្រើនមែនទែន! តើអ្នកចង់លេងល្បែងអវកាសយានិកនិងមនុស្សភពផ្សេងដែរឬទេ? » « បាទ ចង់តើ » សំណាងឆ្លើយ។




សំណាងលេងរហូតដល់ឮសំឡេងជួង។ ពេលដែលពួកគាត់កំពុងដើរទៅថ្នាក់រៀនវិញ រតនាបានឮមិត្តរួមថ្នាក់ពីរនាក់និយាយគ្នា។ ម្នាក់និយាយ « តាមពិតគាត់មិនសូវជាចម្លែកប៉ុន្មានទេ »។



ម្នាក់ទៀតក៏បន្តឆ្លើយ៖ « មែនហើយៗ! គ្រាន់តែគាត់មានវិធីផ្សេងពីយើង »។
រតនានិងមករាក៏និយាយទៅកាន់អ្នកទាំងអស់គ្នា « អូ! អស្ចារ្យណាស់ៗ! »៕

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបន្ថែម៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

មូលនិធិផ្តល់ដោយអង្គការTukTuk និងអង្គការរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ Robert McCurdy និងRoberta Dahl ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង Sally Heinrich ដែលបានចូលរួមកែសម្រួល និងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបន្ថែម